

USAID
ជំនួយពីពលរដ្ឋអាមេរិក

# បច្ចុប្បន្នភាពទីផ្សារ និង ការតាមដានរដូវកាល

ខែតុលា ឆ្នាំ២០២៣

WFP
World Food Programme
SAVING LIVES
CHANGING LIVES

## ប្រទេសកម្ពុជា

កម្មវិធីស្បៀងអាហារពិភពលោកនៃអង្គការសហប្រជាជាតិ សហការជាមួយ
ការិយាល័យទីផ្សារកសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ


**ការិយាល័យទីផ្សារកសិកម្ម (AMO)**
នាយកដ្ឋានផែនការនឹងស្ថិតិ
ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
មៀច យ៉ាឌី meachyady@gmail.com
គេហទំព័រ: https://amis.maff.gov.kh/

**វិភាគ និងធ្វើផែនទីភាពងាយរងគ្រោះ (VAM)**
ផ្នែកស្រាវជ្រាវ វាយតម្លៃ និងតាមដាននៃកម្មវិធីស្បៀងអាហារពិភពលោករបស់អង្គការសហប្រជាជាតិ
Benjamin Scholz benjamin.scholz@wfp.org, ឡុង យ៉ាវ yav.long@wfp.org ,
ជឿ ច័ន្ទវិបុល chanvibol.choeur@wfp.org, ហួយ វណ្ណារ៉េត vannareth.huoy@wfp.org
គេហទំព័រ៖ https://www.wfp.org/countries/cambodia

# បុព្វកថា

**ក្នុងខែតុលា ឆ្នាំ២០២៣ អតិផរណាស្បៀងអាហារសកលនៅតែខ្ពស់** ដោយសារតែជម្លោះអ៊ីស្រាអែល និងប៉ាឡេស្ទីននាពេលថ្មីៗ ការវាយប្រហារជាបន្តបន្ទាប់របស់រុស្ស៊ីទៅលើហេដ្ឋារចនាសម្ព័ន្ធនាំចេញរបស់អ៊ុយក្រែន ការបិទការនាំចេញស្បៀងអាហាររបស់ប្រទេសជាអ្នកផលិតមួយចំនួន និងភាពមិនច្បាស់លាស់ទាក់ទងបាតុភូតអែលនីញ៉ូ មានឥទ្ធិពលលើផលិតកម្មកសិកម្មសកល។

**សន្ទស្សន៍តម្លៃម្ហូបអាហារពិភពលោករបស់ FAO ក្នុងខែតុលា ឆ្នាំ២០២៣ មានស្ថេរភាព បើធៀបនឹងខែមុន (MoM)** ដោយសារតែការធ្លាក់ចុះតម្លៃស្ករ ធញ្ញជាតិ ប្រេងឆា និងសាច់ បានទូទាត់ជាមួយនឹងការកើនឡើងតម្លៃផលិតផលទឹកដោះគោ។ គួរកត់សម្គាល់ថា សន្ទស្សន៍នេះទាបជាងខែដូចគ្នាកាលពីឆ្នាំមុន (YoY) ១០,៩%។ **សន្ទស្សន៍តម្លៃអង្ករសរុបរបស់ FAO នៅក្នុងខែតុលា ឆ្នាំ២០២៣** បានថយចុះ ២,០% ប៉ុន្តែ**នៅតែខ្ពស់ជាងខែដូចគ្នាកាលពីឆ្នាំមុន ២៤,០%។**

**ការបន្តបិទការនាំចេញអង្កររបស់ប្រទេសឥណ្ឌា** បានធ្វើឱ្យមានការកាត់បន្ថយនូវការផ្គត់ផ្គង់អង្ករសកល។ ការបិទការនាំចេញទាំងនេះ បន្ថែមបញ្ហាប្រឈមនៅក្នុងទីផ្សារអង្ករ ដែលតម្លៃបានកើនឡើងពី 15% ទៅ 20% ចាប់តាំងពីខែកញ្ញា ឆ្នាំ២០២២ រួចមកហើយ។ តម្លៃអង្ករសកលត្រូវបានព្យាករថានឹងនឹងកើនឡើង ៦% ក្នុងឆ្នាំ២០២៤ បន្ទាប់ពីបានកើនឡើង ២៨% ក្នុងឆ្នាំ២០២៣។ នៅក្នុងខែតុលា ឆ្នាំ២០២៣ តម្លៃអង្ករនាំចេញពីប្រទេសថៃ បានធ្លាក់ចុះបន្តិច ខណៈតម្លៃអង្ករនាំចេញរបស់ប្រទេសវៀតណាម បានកើនកើនលើង។

ស្ថានភាពនេះ បានបង្កើននូវក្តីព្រួយបារម្ភអំពីសន្តិសុខស្បៀងជាសកល ដោយសារអង្ករជាអាហារចម្បងសម្រាប់មនុស្សជាង ៣ ពាន់លាននាក់។

**បាតុភូតអែលនីញ៉ូបច្ចុប្បន្ន** រំពឹងថានឹងមានកម្រិតខ្លាំងបំផុតកំឡុងខែវិច្ឆិកា ឆ្នាំ២០២៣ ដល់ខែមករា ឆ្នាំ២០២៤ ហើយនឹងចុះខ្សោយជាបន្តបន្ទាប់ ខណៈពេលដែលនៅតែមានសកម្មភាពពីខែមីនា ដល់ខែឧសភា ឆ្នាំ២០២៤។

**ផលិតកម្មកសិកម្ម និងស្បៀងអាហារសកលត្រូវបានព្យាករថានឹងបន្តកើនឡើងក្នុងទសវត្សរ៍ក្រោយ។** ប៉ុន្តែមានការព្យាករថាវានឹងកើនឡើងយឺត ដោយសារតែការកើនឡើងយ៉ាងខ្លាំងនៃតម្លៃធាតុចូលកសិកម្ម ក្នុងរយៈពេលពីរឆ្នាំចុងក្រោយនេះ។

**ដើម្បីស្វែងយល់ពីឥទ្ធិពលនៃបញ្ហាទាំងនេះ លើភាពមានស្បៀង និងលទ្ធភាពទទួលបានស្បៀង នៅតាមផ្សារនានាក្នុងប្រទេសកម្ពុជា** កម្មវិធីស្បៀងអាហារពិភពលោក (WFP) និងការិយាល័យទីផ្សារកសិកម្ម (AMO) នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (MAFF) បាន សហការគ្នាតាមដានតម្លៃស្បៀងអាហារសំខាន់ៗ និងដំណើរការរបស់ផ្សារចំនួន៥៦។ ប្រធានផ្សារ និងអាជីវករ ចំនួនប្រហែល ១.០០០ នាក់ ត្រូវបានសម្ភាសន៍ជារៀងរាល់ពីរសប្តាហ៍ ដោយវាយតម្លៃពីការផ្គត់ផ្គង់ និងតម្រូវការ។ តម្លៃប្រេងសាំង ប្រេងម៉ាស៊ូត និងប្រាក់ឈ្នួលពលកម្មក៏ត្រូវបានតាមដានផងដែរ។

# មាតិកា


**១. របកគំហើញសំខាន់ៗ** ៣

**២. លទ្ធផល**

ការដំណើរការរបស់ផ្សារ ៤

ការទៅផ្សារ៖ ទិន្នាការអតិថិជន ៥

ថ្នាក់ជាតិ៖ តម្លៃនៃកញ្ចប់ស្បៀងអាហារមូលដ្ឋាន ៦

ថ្នាក់ជាតិ៖ និន្នាការតម្លៃអង្ករចម្រុះ ស៊ុតទា និងត្រីកួន ៧

ថ្នាក់ជាតិ៖ និន្នាការតម្លៃត្រីផ្ទក់ សាច់ជ្រូក និងប្រេងឆា ៨

ថ្នាក់ក្រោមជាតិ៖ ភាពខុសគ្នា និងបម្រែបម្រួលនៃតម្លៃនៅជនបទ និងទីប្រជុំជន ៩

ប្រាក់ឈ្នួលពលកម្ម និងកម្លាំងទិញស្បៀងអាហារ ១០

ការតាមដានរដូវកាល៖ របាយទឹកភ្លៀង ១១

ការតាមដានរដូវកាល៖ ស្ថានភាពរុក្ខជាតិ និងដំណាំ ១២

**៣. បរិបទ**

ពាណិជ្ជកម្ម ១៣

ការឆ្លើយតបផ្នែកនយោបាយ ១៤

**៤. វិធីសាស្ត្រ និងទីតាំងផ្សារ** ១៥

**៥. ឧបសម្ព័ន្ធទី១**

បម្រែបម្រួលថ្លៃលក់រាយ ១៦

**៦. ឧបសម្ព័ន្ធទី២**

បម្រែបម្រួលថ្លៃលក់ដុំ ១៧

**៧. ឧបសម្ព័ន្ធទី៣**

តម្លៃនៃកញ្ចប់ស្បៀងអាហារមូលដ្ឋាន ១៨

## កត្តាបរិស្ថានដែលមាន ឥទ្ធិពលលើតម្លៃ

**កំណើនសេដ្ឋកិច្ច**

២០២២ ៥.២%

២០២៣ ៥.៣% (ព្យាករណ៍)

*តាំងពីដើមឆ្នាំមក សន្ទស្សន៍តម្លៃទំនិញប្រើប្រាស់រួម (CPI) និងសន្ទស្សន៍តម្លៃស្បៀងអាហារកម្ពុជា*(FPI) មាននិន្នាការកើនឡើង។ ក្នុងខែតុលា ឆ្នាំ២០២៣ សន្ទស្សន៍ទាំង២ បានកើនឡើងបង្គួរ ធៀបនឹងខែដូចគ្នាកាលពីឆ្នាំ២០២២ ហើយខ្ពស់ជាងឆ្នាំ២០២១គួរឱ្យកត់សម្គាល់។ គ្រួសារកម្ពុជាចំណាយស្មើរតែពាក់កណ្តាល (៥២%) នៃប្រាក់ចំណូលរបស់ខ្លួនលើស្បៀងអាហារ។ គ្រួសារក្នុងក្រុមចំណាយទាបបំផុតបានចំណាយ រហូតដល់៥៨% (CSES ២០២១)។*

**អតិផរណា**




*<u>តម្លៃប្រេងឥន្ធនៈនៅកម្ពុជា</u> ក្នុងខែតុលា ឆ្នាំ២០២៣ បានថយចុះបង្គួរ។ ការថយចុះតម្លៃប្រេងម៉ាស៊ូត ទំនងជាដោយសារការលើកលែងការរឹតបន្តឹងការនាំចេញប្រេងម៉ាស៊ូតភាគច្រើនរបស់ប្រទេសរុស្ស៊ី។*

**ប្រេងឥន្ធនៈ**




# សង្ខេបរបកគំហើញសំខាន់ៗ

ក្នុងខែតុលា ឆ្នាំ២០២៣ កញ្ចប់ស្បៀងអាហារមូលដ្ឋាន (BFB) បានកើនឡើង ២,១% ធៀបនឹងខែមុន (MoM) ដល់តម្លៃ ២៨,៥ ដុល្លារ ក្នុងម្នាក់ ក្នុងមួយខែ។ ការកើនឡើងនេះដោយសារ**ការកើនឡើងតម្លៃស្បៀងអាហារនៅតំបន់ទីប្រជុំជន** ដែលនៅតែមានតម្លៃខ្ពស់ជាងកាលពីឆ្នាំមុនបន្តិច (YoY)។

បើទោះជាតម្លៃស្បៀងអាហារ ដែលបានតាមដានភាគច្រើនមានការប្រែប្រួលតិចតួច (<៥% MoM) ក្នុងខែតុលា **តម្លៃអង្ករបន្តកើនឡើង ២៨,៨% ខ្ពស់ជាងខែដូចគ្នាកាលពីឆ្នាំមុន។** មួយវិញទៀត តម្លៃត្រកួនបានកើនឡើង ១១,១% MoM ស្របនឹងបម្រែបម្រួលតម្លៃតាមរដូវកាលរបស់វា។ ទោះបីជាតម្លៃមានស្ថេរភាពក៏ដោយ ក៏ត្រីផ្អក់នៅតែមានតម្លៃខ្ពស់ជាងកាលពីឆ្នាំ២០២២ តាំងពីខែមិថុនា ឆ្នាំ២០២៣ មកម្ល៉េះ ដោយមានកំណើនខ្ពស់ ១៥,៥% YoY ក្នុងខែតុលា។

ការកើនឡើងតម្លៃស្បៀងអាហារនេះ គួបផ្សំនឹងការថយចុះប្រាក់ឈ្នួល **បានធ្វើឱ្យអំណាចទិញរបស់ក្រុមងាយរងគ្រោះកាន់តែថយចុះ។** ទោះជាយ៉ាងណាក៏ដោយ ចំនួនអតិថិជនមកផ្សារក្នុងខែតុលាមានការកើនឡើង ទំនងជាដោយសារតែការកើនឡើងនូវតម្រូវការកំឡុងពេលបុណ្យភ្ជុំបិណ្ឌ។ ជាងនេះទៅទៀត ផ្សារមានដំណើរការល្អ ដោយសារតែតម្លៃទំនិញមានស្ថេរភាព។

ក្នុងខែតុលា តំបន់មួយចំនួនក្នុងប្រទេសកម្ពុជាទទួលបានទឹកភ្លៀងខុសធម្មតា បង្កឱ្យមានជា**ជំនន់ទឹកភ្លៀង ដែលប៉ះពាល់ជាអវិជ្ជមានដល់ការដាំដុះដំណាំ។** គិតត្រឹមចុងខែតុលា ផ្ទៃដីដាំដុះស្រូវរដូវវស្សាប្រមាណ ៦២% បានប្រមូលផលរួចរាល់។ ប្រទេសកម្ពុជាត្រូវបានព្យាករថានឹងទទួលបានទឹកភ្លៀងកម្រិតធម្មតា ប៉ុន្តែសីតុណ្ហភាពនឹងខ្ពស់ជាងធម្មតា ដោយសារតែបាតុភូតអែលនីញូ ដែលកំពុងបន្ត ដែលរំពឹងទុកថានឹងបន្តរហូតដល់ពាក់កណ្តាលឆ្នាំ២០២៤។

# ការដំណើរការរបស់ផ្សារ

ក្នុងខែតុលា ឆ្នាំ២០២៣ សន្ទស្សន៍ដំណើរការរបស់ផ្សារ* (MFI) បានកើនឡើងពេញមួយខែធៀបនឹងខែមុន ដោយសារតែការកើនឡើងនូវស្ថេរភាពតម្លៃទំនិញសំខាន់ៗ និងភាពអាចរកបានជាក់ស្តែងនៃទំនិញចាំបាច់ក្នុងបរិមាណគ្រប់គ្រាន់។ ការកើនឡើងនេះទំនងជាដោយសារតែការប្រារព្ធពិធីបុណ្យសាសនាដ៏ធំរបស់កម្ពុជា (បុណ្យភ្ជុំបិណ្ឌ) តាំងពីដើមខែមក។ ប្រធានផ្សារ និងអ្នកលក់តាមបណ្តាផ្សារត្រូវបានសម្ភាសន៍ស្តីពីស្ថានភាពនៃការផ្គត់ផ្គង់ស្បៀងអាហារ។ នៅក្នុងខែតុលា មានប្រធានផ្សារ និងអ្នកលក់ដែលបានសម្ភាសន៍ចំនួន ៩% ដែលបានរាយការណ៍ថាមានការកើនឡើងតម្លៃផ្គត់ផ្គង់អង្ករ និងស្បៀងអាហារសំខាន់ៗដទៃទៀត។




** សន្ទស្សន៍ដំណើរការផ្សារ (MFI) វាស់វែងពីដំណើរការរបស់ផ្សារដែលបានតាមដាន ដោយផ្អែកលើសមាសធាតុសំខាន់ៗ៖ ភាពចម្រុះនៃទំនិញចាំបាច់ ភាពអាចរកបានជាក់ស្តែងនៃទំនិញក្នុងបរិមាណគ្រប់គ្រាន់ តម្លៃដែលអាចព្យាករបាននិងមានស្ថេរភាព និងភាពធន់នៃខ្សែច្រវាក់ផ្គត់ផ្គង់។ សមាសធាតុនីមួយៗនៅក្នុងសន្ទស្សន៍ដំណើរការផ្សារសង្ខេប គឺជាសន្ទស្សន៍ ដែលមានពីលេខ០ ដល់លេខ១០ ហើយតម្លៃកាន់តែខ្ពស់ បង្ហាញថា ផ្សារមានដំណើរការកាន់តែល្អកំឡុងពេលតាមដាន។ សន្ទស្សន៍ដំណើរការផ្សារជារួមគឺជាការបញ្ចូលគ្នានៃសមាសធាតុទាំងបួន។ លម្អិតពីវិធីសាស្ត្ររបស់សន្ទស្សន៍ដំណើរការផ្សារ។ ចាប់ពីពាក់កណ្តាលខែកញ្ញា ឆ្នាំ២០២២មក ព័ត៌មានស្តីពីទំនិញមិនមែនស្បៀងអាហារក៏ត្រូវបានបញ្ចូលទៅក្នុងការវិភាគនេះដែរ។ ចាប់ពីខែមេសា ឆ្នាំ២០២៣មក ការគណនា MFI និងសមាសធាតុសំខាន់ៗត្រូវបានកែសម្រួលដើម្បីបង្ហាញព័ត៌មានកាន់តែសុក្រិត។*

# ការនៅផ្សារ៖ ទិន្នាការអតិថិជន

នៅក្នុងខែតុលា ឆ្នាំ២០២៣ មានការកើនឡើងគួរឱ្យកត់សម្គាល់នូវចំនួនអតិថិជនទៅផ្សារបើធៀបនឹងខែមុន បើទោះជាវាបានថយចុះបន្តិចនៅចុងខែ។ ការកើនឡើងនេះអាចដោយសារតែការប្រារព្ធពិធីបុណ្យសាសនាដ៏ធំរបស់កម្ពុជា (បុណ្យភ្ជុំបិណ្ឌ) ដែលបានចាប់ផ្តើមតាំងពីដើមខែ។




បម្រែបម្រួលនៃចំនួនអតិថិជន*មកផ្សារ

*ប្រធានផ្សារ និងអ្នកលក់តាមបណ្តាផ្សារចំនួន ៥៦ កន្លែង ដែលបានតាមដានតម្លៃនៅទូទាំងប្រទេស ក៏ត្រូវបានសម្ភាសន៍ស្តីពីភាពងាយស្រួលក្នុងការធ្វើដំណើរទៅផ្សារ និងចំនួនអតិថិជនទៅផ្សារនៅសប្តាហ៍ទី១ និងសប្តាហ៍ទី៣ នៃខែនីមួយៗ ដោយប្រៀបធៀបទៅនឹងរយៈពេលពីសប្តាហ៍មុន។ តម្លៃលេខបង្ហាញពីបម្រែបម្រួលនៃចំនួនអតិថិជនត្រូវបានគណនាដោយប្រើសន្ទស្សន៍កំណើន/តំហាយ (diffusion index) ដើម្បីតាមដានពីការប្រែប្រួលអតិថិជនមកផ្សារក្នុងសេរីពេលវេលា។

# ថ្នាក់ជាតិ៖ តម្លៃនៃកញ្ចប់ស្បៀងអាហារមូលដ្ឋាន

ក្នុងខែតុលា ឆ្នាំ២០២៣ តម្លៃកញ្ចប់ស្បៀងអាហារមូលដ្ឋាន[1] (BFB) បានបន្តកើនឡើងបង្គួរ គឺកើន ២,២% ធៀបនឹងខែមុន (MoM) ដោយមានតម្លៃ ១១៦.៦៦៣ រៀល/ម្នាក់/ខែ (ប្រហែល ២៨,៥ ដុល្លារ)។ តម្លៃ BFB នៅផ្សារតំបន់ទីប្រជុំជនបានកើនឡើង (+៣,២% – ២៩,៣ ដុល្លារ) ខ្ពស់ជាងតម្លៃ BFB នៅផ្សារតំបន់ជនបទ (+០,១% – ២៧,១ ដុល្លារ)។

BFB មានតម្លៃទាបជាងខែដូចគ្នាកាលពីឆ្នាំមុន (YoY) ១,២%។ ប៉ុន្តែ BFB នៅផ្សារតំបន់ទីប្រជុំជនមានតម្លៃខ្ពស់ជាងខែដូចគ្នាកាលពីឆ្នាំមុនបន្តិច។ គួរកត់សម្គាល់ថា BFB មានតម្លៃខ្ពស់ជាងខែដូចគ្នាកាលពីឆ្នាំ២០២១ ចំនួន ៥,១%។




[1] តម្លៃនៃកញ្ចប់ស្បៀងអាហារមូលដ្ឋាន (BFB) របស់ WFP ត្រូវបានគណនាដើម្បីជាជំនួយក្នុងការបកស្រាយផលប៉ះពាល់នៃការប្រែប្រួលតម្លៃស្បៀងប្រចាំខែលើតម្លៃរបបអាហារប្រកបដោយអាហារូបត្ថម្ភដែលបានទទួលទាន់នៅកម្ពុជា។

[2] ផ្សារនៅទីប្រជុំជនសំដៅដល់ផ្សារដែលស្ថិតនៅទីរួមខេត្ត ហើយផ្សារដទៃទៀតចាត់ទុកថាជាផ្សារនៅជនបទ។

## កញ្ចប់ស្បៀងអាហារមូលដ្ឋាន (BFB) របបអាហារប្រចាំថ្ងៃសម្រាប់មនុស្សម្នាក់



*កញ្ចប់ស្បៀងអាហារមូលដ្ឋានមានបញ្ចូលនូវស្បៀងអាហារសំខាន់ៗ រួមមាន អង្ករចម្រុះ ត្រីផ្ទក់ សាច់ជ្រូក ស៊ុតទា ប្រេងឆា ដំឡូងជ្វា និងត្រកួន ដែលផ្តល់ថាមពលអប្បបរមាចាំបាច់ចំនួន ១.៩៣៧ កាឡូរី សម្រាប់មនុស្សម្នាក់ក្នុងមួយថ្ងៃ។ កញ្ចប់ស្បៀងអាហារមូលដ្ឋានត្រូវបានវិភាគដោយផ្អែកលើកញ្ចប់ចំណាយអប្បបរមា (MEB) នៅប្រទេសកម្ពុជា របស់ WFP។ សូមមើលឧបសម្ព័ន្ធទី ៣ សម្រាប់ព័ត៌មានពីវិធីសាស្ត្រ។*

# ថ្នាក់ជាតិ៖ និន្នាការតម្លៃអង្ករ ស៊ុតទា និងត្រកួន

ក្នុងខែតុលា ឆ្នាំ២០២៣ តម្លៃលក់រាយអង្ករចម្រុះមានស្ថេរភាពធៀបនឹងខែមុន (MoM) ប៉ុន្តែបានកើនឡើងគួរឱ្យកត់សម្គាល់ ២៨,៨% ធៀបនឹងខែដូចគ្នាកាលពីឆ្នាំមុន (YoY)។ តម្លៃលក់រាយស៊ុតទាបានកើនឡើង ២,៥% MoM តែថយចុះ ៥,១% YoY។ តម្លៃលក់រាយត្រកួនបានកើនឡើង ១១,១% MoM ប៉ុន្តែថយចុះ ២៩,៧% YoY។

*សូមមើលឧបសម្ព័ន្ធទី១ និងទី២ សម្រាប់តម្លៃនៃស្បៀងអាហារផ្សេងៗទៀត។*




*សម្គាល់៖*

*- ត្រកួនគឺបន្លែដែលត្រូវបានទទួលទានជាទូទៅនៅប្រទេសកម្ពុជា ហើយនិន្នាការតម្លៃរបស់វាមិនបង្ហាញពីការឡើងចុះតម្លៃបន្លែផ្សេងទៀតនៅក្នុងឧបសម្ព័ន្ធនោះទេ។*

*- តម្លៃស្បៀងអាហារត្រូវបានប្រមូលតាមទូរស័ព្ទ*

# ថ្នាក់ជាតិ៖ និន្នាការតម្លៃត្រីផ្ទក់ សាច់ជ្រូក និងប្រេងឆា

ក្នុងខែតុលាឆ្នាំ២០២៣ តម្លៃលក់រាយត្រីផ្ទក់ សាច់ជ្រូក និងប្រេងឆា មានស្ថេរភាពធៀបនឹងខែមុន (MoM)។ ប៉ុន្តែ នៅពេលធៀបនឹងខែដូចគ្នាកាលពីឆ្នាំមុន (YoY) តម្លៃមាននិន្នាការខុសគ្នាគួរឱ្យកត់សម្គាល់។ តម្លៃលក់រាយត្រីផ្ទក់បានកើនឡើង ១៥,៤% YoY ខណៈតម្លៃលក់រាយប្រេងឆាមានតម្លៃទាបគួរឱ្យកត់សម្គាល់ គឺ ១៦,៧% ហើយសាច់ជ្រូកមានតម្លៃទាបគួរឱ្យកត់សម្គាល់ គឺ ១៤,០%។

*សូមមើលឧបសម្ព័ន្ធទី១ និងទី២ សម្រាប់តម្លៃស្បៀងអាហារផ្សេងៗទៀត។*




*សម្គាល់៖ តម្លៃស្បៀងអាហារត្រូវបានប្រមូលតាមទូរស័ព្ទ*

# ថ្នាក់ក្រោមជាតិ៖ ភាពខុសគ្នា និងបម្រែបម្រួលនៃតម្លៃនៅជនបទ និងទីប្រជុំជន

ក្នុងខែតុលា ឆ្នាំ២០២៣ តម្លៃមធ្យមលក់រាយស្បៀងអាហារដែលបានតាមដានភាគច្រើន (ក្រាហ្វិកខាងក្រោមឆ្វេង) មានទិសដៅប្រែប្រួលដូចគ្នា ទាំងនៅផ្សារជនបទ និងផ្សារទីប្រជុំជន។ តម្លៃស្បៀងអាហារទាំងអស់មានការប្រែប្រួលបង្គួរប៉ុណ្ណោះ (≤៥%) ធៀបនឹងខែមុន លើកលែងតម្លៃត្រកួន និងតម្លៃដំឡូងផ្កាពណ៌លឿង។ តម្លៃត្រកួនបានកើនឡើងគួរឱ្យកត់សម្គាល់នៅទីប្រជុំជនចំនួន ១៧,១% ខណៈតម្លៃដំឡូងផ្កាបានថយចុះគួរឱ្យកត់សម្គាល់នៅទីប្រជុំជនចំនួន ៩,១% ធៀបនឹងខែកញ្ញា ឆ្នាំ២០២៣។

តម្លៃកញ្ចប់ស្បៀងអាហារមូលដ្ឋានរបស់ WFP មានការប្រែប្រួលតាមបណ្តាខេត្ត (ផែនទីខាងក្រោមស្តាំ) ដោយនៅផ្សារស្ទឹងត្រែង ក្នុងខេត្តស្ទឹងត្រែង (៣១,៨ ដុល្លារ) គឺខ្ពស់ជាងតម្លៃមធ្យមថ្នាក់ជាតិ ១២% ខណៈនៅផ្សារឈើកាច់ ក្នុងខេត្តព្រៃវែង (២៤,៥ ដុល្លារ) គឺទាបជាងតម្លៃមធ្យមថ្នាក់ជាតិ ១៥%។ តម្លៃកញ្ចប់ស្បៀងអាហារដែលខ្ពស់ជាងតម្លៃមធ្យមថ្នាក់ជាតិពិសេសតម្លៃខ្ពស់ជាង ១០% ភាគច្រើនមាននៅផ្សារនៅទីប្រជុំជន។

**បម្រែបម្រួលប្រចាំខែ (%) នៃតម្លៃលក់រាយស្បៀងអាហារសំខាន់ៗ**
ខែកញ្ញា ឆ្នាំ២០២៣ និង ខែតុលា ឆ្នាំ២០២៣




**តម្លៃកញ្ចប់ស្បៀងអាហារមូលដ្ឋានតាមផ្សារ ឬខេត្ត ធៀបនឹង តម្លៃកញ្ចប់ជាមធ្យមថ្នាក់ជាតិ** (ខែតុលា ឆ្នាំ២០២៣)



| បម្រែបម្រួលពីតម្លៃមធ្យមថ្នាក់ជាតិ | ភាគរយនៃផ្សារនៅ ជនបទ | ភាគរយនៃផ្សារនៅ ទីប្រជុំជន |
|---|---|---|
| ≥ ១០% ខ្ពស់ជាង | 0% | ១00% |
| ៥% ទៅ ១០% ខ្ពស់ជាង | 0% | ១00% |
| < ៥% ខ្ពស់ជាង | ៣៨% | ៦២% |
| < ៥% ទាបជាង | ៥៣% | ៤៧% |
| ៥% ទៅ ១០% ទាបជាង | ៥៦% | ៤៤% |
| ≥ ១០% ទាបជាង | ១00% | 0% |

*សម្គាល់៖*
*- ទិន្នន័យតម្លៃពីផ្សារចំនួន៥៦. មើលវិធីសាស្ត្រសម្រាប់ព័ត៌មានលម្អិត។*
*- តម្លៃស្បៀងអាហារត្រូវបានប្រមូលតាមទូរស័ព្ទ*

# ប្រាក់ឈ្នួលពលកម្ម និងកម្លាំងទិញស្បៀងអាហារ

ប្រាក់ឈ្នួលពលកម្មសម្រាប់កម្មករក្នុងវិស័យកសិកម្ម និងសំណង់ត្រូវបានប្រមូលជារៀងរាល់ខែនៅទូទាំងប្រទេសដោយការិយាល័យទីផ្សារកសិកម្ម (AMO) នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (MAFF)។ ក្នុងខែតុលា ឆ្នាំ២០២៣ ប្រាក់ឈ្នួលពលកម្មមធ្យមថ្នាក់ជាតិ[1] សម្រាប់កម្មករគ្មានជំនាញបានថយចុះ ៣,១% ធៀបនឹងខែមុន (MoM) គឺមានតម្លៃ ៣៥.៥០០ រៀលក្នុងមួយថ្ងៃ (ប្រហែល ៨,៧ ដុល្លារ)។ ប៉ុន្តែ តម្លៃនេះខ្ពស់ជាងខែដូចគ្នាកាលពីឆ្នាំមុន ៦,២%។

កម្លាំងទិញស្បៀងអាហារ (ToT) ត្រូវបានប្រើសម្រាប់វាយតម្លៃពីកម្លាំងទិញស្បៀងអាហាររបស់គ្រួសារ ហើយត្រូវបានវាស់វែងដោយប្រើផលធៀបរវាងអត្រាប្រាក់ឈ្នួលកម្មករគ្មានជំនាញប្រចាំថ្ងៃ និងតម្លៃមធ្យមកញ្ចប់ស្បៀងអាហារមូលដ្ឋានប្រចាំថ្ងៃ[2]។ ក្នុងខែតុលា ឆ្នាំ២០២៣ ToT បានបន្តនិន្នាការថយចុះ ដល់ ៥,១% MoM បង្ហាញពីការថយចុះនៃលទ្ធភាពទិញកញ្ចប់ស្បៀងអាហារមូលដ្ឋានរបស់កម្មករគ្មានជំនាញ។ ការថយចុះនេះដោយសារកំណើនតម្លៃកញ្ចប់ស្បៀងអាហារមូលដ្ឋាន និងការថយចុះនៃប្រាក់ឈ្នួលពលកម្ម។ ប៉ុន្តែ វាមានតម្លៃខ្ពស់ជាងខែតុលា ឆ្នាំ២០២២ គួរឱ្យកត់សម្គាល់គឺ ៧,៥%។

**ប្រាក់ឈ្នួលពលកម្ម**
(ខែតុលា ឆ្នាំ២០២៣)




**កម្លាំងទិញស្បៀងអាហារ**
(ខែតុលា ឆ្នាំ២០២៣)




*[1] នេះជាប្រាក់ឈ្នួលពលកម្ម ដែលមិនទាន់បានកែសម្រួលជាមួយអតិផរណា*

*[2] តម្លៃកញ្ចប់ស្បៀងអាហារមូលដ្ឋាន (BFB) ត្រូវបានគណនាជារៀងរាល់ខែដើម្បីបង្ហាញពីតម្លៃក្នុងមួយខែ។ ប៉ុន្តែ ដើម្បីគណនាកម្លាំងទិញស្បៀងអាហារ (ToT) តម្លៃក្នុងមួយខែនេះត្រូវបានបំលែងទៅជាតម្លៃក្នុងមួយថ្ងៃ ដើម្បីផ្តល់តម្លៃប៉ាន់ស្មានក្នុងមួយថ្ងៃ។*

# ការតាមដានរដូវកាល៖ របាយទឹកភ្លៀង

ក្នុងខែតុលា ឆ្នាំ២០២៣ កម្ពុជាទទួលបានទឹកភ្លៀងជាមធ្យមសរុប* ខ្ពស់ជាងមធ្យមភាគច្រើនឆ្នាំ (ក្រាហ្វិកខាងក្រោមខាងឆ្វេង)។ ខេត្តភាគច្រើន ពិសេសនៅភាគខាងលិចប្រទេស ទទួលបានទឹកភ្លៀងខ្ពស់ជាងធម្មតាគួរឱ្យកត់សម្គាល់ ដែលបង្កឱ្យមានជាជំនន់ទឹកភ្លៀង។ ប៉ុន្តែខេត្តភាគខាងកើតប្រទេសទទួលបានទឹកភ្លៀងទាបជាងមធ្យមភាគច្រើនឆ្នាំបន្តិច (ផែនទីខាងក្រោមខាងស្តាំ)។

ការព្យាករ El Niño, La Niña និង Southern Oscillation (ENSO) បានបង្ហាញថា បាតុភូតអែលនីញ៉ូរំពឹងថានឹងបន្តរហូតដល់ខែឧសភា ឆ្នាំ២០២៤ ធ្វើឱ្យមានស្ថានភាពកាន់តែក្តៅ និងកាត់តែស្ងួត។ ផ្អែកតាមការព្យាករតាមរដូវកាលរបស់ International Research Institute (IRI) of Columbia University and European Centre for Medium-Range Weather Forecasts (ECMWF) ចន្លោះខែវិច្ឆិកា ឆ្នាំ២០២៣ ដល់ខែមករា ឆ្នាំ២០២៤ ខេត្តភាគច្រើននៃប្រទេសកម្ពុជាទំនងជាទទួលបានទឹកភ្លៀងធម្មតា ប៉ុន្តែនឹងមានធាតុអាកាសក្តៅជាងធម្មតា។

## បរិមាណទឹកភ្លៀងមធ្យមថ្នាក់ជាតិ (ខែតុលា ឆ្នាំ២០២៣) និងប្រតិទិនដាំដុះតាមរដូវកាល




| | មករា–កុម្ភៈ | មីនា–មេសា | ឧសភា–មិថុនា | កក្កដា–តុលា | វិច្ឆិកា–ធ្នូ |
|---|---|---|---|---|---|
| ស្រូវរដូវប្រាំង | ដាំដុះ | ប្រមូលផល | | | រៀបចំដី និង សាបព្រោះ |
| ស្រូវរដូវវស្សា | ប្រមូលផល | | រៀបចំដី និង សាបព្រោះ | ស្ទូង / ដាំដុះ | ប្រមូលផល |

*ប្រភព៖ ទិន្នន័យទឹកភ្លៀងពី CHIRPS និងវិភាគដោយ WFP*

## ភាពមិនប្រក្រតីនៃទឹកភ្លៀង ក្នុងខែតុលា ឆ្នាំ២០២៣




*ប្រភព៖ ទិន្នន័យទឹកភ្លៀងពី CHIRPS និងវិភាគដោយ WFP*

** កម្ពស់ទឹកភ្លៀងជាមធ្យមសរុបសម្រាប់ខែមួយគឺជាផលបូកនៃកម្ពស់ទឹកភ្លៀងក្នុងរយៈពេល ៣ដេកាត (រៀងរាល់១០ថ្ងៃ) ក្នុងខែនោះ។*

# ការតាមដានរដូវកាលៈ ស្ថានភាពរុក្ខជាតិ និងដំណាំ

នៅក្នុងខែតុលា ឆ្នាំ២០២៣ រុក្ខជាតិ ដែលស្ថិតនៅតំបន់ដាំដុះដំណាំភាគច្រើននៃប្រទេសកម្ពុជា មានស្ថានភាពចន្លោះពីធម្មតាទៅប្រសើរជាងធម្មតា (ផែនទីខាងស្តាំ)។ ប៉ុន្តែ រុក្ខជាតិ ដែលស្ថិតនៅតំបន់ទំនាបពិសេសតំបន់ជុំវិញទន្លេសាប និងបឹងទន្លេសាប មានស្ថានភាពទាបជាងធម្មតា ដែលទំនងបណ្តាលមកជំនន់ទឹកភ្លៀងកាលពីដើមខែតុលា។

ផ្ទៃដីដាំដុះស្រូវវស្សាសរុបសម្រេចបានមានចំនួនច្រើនជាងឆ្នាំមុន ៩% ផ្អែកតាមរបាយការណ៍ទស្សនវិស័យកំណើនស្រូវក្នុងខែតុលា ឆ្នាំ២០២៣ នៃប្រព័ន្ធព័ត៌មានសន្តិសុខស្បៀងអាស៊ាន) បើទោះជាមានផ្ទៃដីដាំដុះប្រមាណ ៣២.៩៥០ ហិកតា ត្រូវបានប៉ះពាល់ដោយសារជំនន់ទឹកភ្លៀងក៏ដោយ (របាយការណ៍ HRF ស្តីពីស្ថានភាពទឹកជំនន់ លើកទី១ ខែតុលា ឆ្នាំ២០២៣)។ គិតត្រឹមខែតុលា ការប្រមូលផលស្រូវរដូវវស្សានៅទូទាំងប្រទេស សម្រេចបានចំនួន ៦២% (របាយការណ៍ទស្សនវិស័យកំណើនស្រូវក្នុងខែតុលា ឆ្នាំ២០២៣ នៃប្រព័ន្ធព័ត៌មានសន្តិសុខស្បៀងអាស៊ាន)។

**ភាពមិនប្រក្រតីនៃសន្ទស្សន៍ភាពខុសគ្នានៃរុក្ខជាតិ (NDVI)**
**ក្នុងខែតុលា ឆ្នាំ២០២៣**




*ប្រភព៖ NDVI ពី MODIS និងវិភាគដោយ WFP*

# ពាណិជ្ជកម្ម

ក្នុងរយៈពេលដប់ខែដំបូង ឆ្នាំ២០២៣ ការនាំចេញផ្លូវការសរុបរបស់កម្ពុជាមានស្ថេរភាព ជាមួយនឹងការកើនឡើងបន្តិចគឺ ៣,១% ធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន មានតម្លៃ ១៩.៣៣៨ លានដុល្លារ។ ការនាំចេញទំនិញជាស្បៀងអាហារចំនួន ១.៦៦៧ លានដុល្លារ (ក្រាហ្វិកខាងស្តាំ) ដែលរួមមាន៖ ធញ្ញជាតិសរុបចំនួន ១.៣១០ លានដុល្លារ (+៥៣% YoY ដោយសារការនាំចេញអង្ករបន្ថែមចំនួន ៦.៥០០ តោនទៅកាន់ប្រទេសឥណ្ឌូនេស៊ី ក្នុងខែតុលា ឆ្នាំ២០២៣ ក៏ដូចជាការកើនឡើងតម្លៃអង្ករសកល) និងអាហារដទៃទៀត (ដូចជា៖ សាច់/សំណល់សាច់/គ្រឿងក្នុង ដែលអាចបរិភោគបាន បន្លែដែលអាចបរិភោគបាន ឫស/មើម និងខ្លាញ់សត្វ ប្រេងរុក្ខជាតិ) ចំនួន ៣៥៧ លានដុល្លារ (+២% YoY)។ ការនាំចេញអង្ករមានចំនួន ៥២៩.៩២៤ តោន (មានតម្លៃស្មើ ៣៧៧,៥ លានដុល្លារ) សម្រេចបានជិត ៧៦% នៃគោលដៅនាំចេញប្រចាំឆ្នាំ (៧០០.០០០ តោន) ហើយការនាំចេញស្រូវមានចំនួន ៣,៣ លានតោន (មានតម្លៃស្មើនឹង ៨៦២,៤៦ លានដុល្លារ) ត្រូវបាននាំចេញក្នុងរយៈពេលដូចគ្នា (ដកស្រង់ដោយកាសែតប្រៀសញូវ ថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០២៣)។

ក្នុងរយៈពេលដប់ខែដំបូង ឆ្នាំ២០២៣ ការនាំចូលជាផ្លូវការសរុបរបស់កម្ពុជាបានបានថយចុះគួរឱ្យកត់សម្គាល់ គឺ ២១% ធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន មានតម្លៃ ២០.២៩២ លានដុល្លារ។ មូលហេតុចម្បងនៃការថយចុះនេះ គឺដោយសារតែការថយចុះនៃការនាំចូលទំនិញមិនមែនស្បៀងអាហារពីប្រទេសផលិតសំខាន់ៗ ដូចជា ប្រទេសសាំងហ្គាពួរ តៃវ៉ាន់ ថៃ និងវៀតណាម។ ការថយចុះនេះ អាចដោយសារតែការរំខានក្នុងខ្សែច្រវាក់ផ្គត់ផ្គង់ និងការផ្លាស់ប្តូរនៃតម្រូវការ បង្កឡើងដោយពហុវិបត្តិសកល ដូចជា ភាពតានតឹងផ្នែកភូមិសាស្ត្រនយោបាយ ផលប៉ះពាល់នៃបាតុភូតអែលនីញូ និងការរាតត្បាតជំងឺ។ វិបត្តិអស់ទាំងនេះ បានធ្វើឱ្យមានការកើនឡើងនូវបញ្ហាបំណុល អតិផរណា និងបង្អាក់ដល់ការផលិត។

ក្នុងចំនោមការនាំចូលសរុប មានទំនិញជាស្បៀងអាហារចំនួន ១.០០៩ លានដុល្លារ ដែលរួមមាន៖ ធញ្ញជាតិសរុបចំនួន ៦៣ លានដុល្លារ (+២៧% YoY) និងអាហារដទៃទៀតចំនួន ៩៤៦ លានដុល្លារ (+៧% YoY)។ ក្នុងរយៈពេលដូចគ្នា ប្រទេសកម្ពុជាក៏បាននាំចូលជីកសិកម្មចំនួន ២៦៤ លានដុល្លារ (+១៧% YoY) ភាគច្រើនមកពីប្រទេសវៀតណាម ថៃ និងចិន។

## សមតុល្យពាណិជ្ជកម្មកម្ពុជា (គិតជា លានដុល្លារ) នៃក្រុមទំនិញសំខាន់ៗ ត្រឹម ខែតុលា ឆ្នាំ២០២៣




*ប្រភព៖ អគ្គនាយកដ្ឋានគយនិងរដ្ឋាករ ចូលថ្ងៃទី ១៣ ខែវិច្ឆិកា ឆ្នាំ២០២៣*

# ការឆ្លើយតបផ្នែកនយោបាយ

## គោលនយោបាយឆ្លើយតបលើការគាំពារសង្គម

ចាប់តាំងពីពាក់កណ្តាលឆ្នាំ២០២០ មក រដ្ឋាភិបាលកម្ពុជា បានផ្តួចផ្តើមកម្មវិធីផ្ទេរសាច់ប្រាក់ដ៏ទូលំទូលាយមួយចំនួន ក្នុងគោលបំណងជួយដល់គ្រួសារក្រីក្រ និងងាយរងគ្រោះ ដែលរងផលប៉ះពាល់ដោយជំងឺរាតត្បាត ទឹកជំនន់ និង អតិផរណា ដែលបានកាត់បន្ថយអំណាចទិញរបស់ពួកគេ។ គិតចាប់ពីថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២០ ដល់ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០២៣ មាន ៦៩៨.៥៨៥ គ្រួសារ បានទទួលប្រាក់ឧបត្ថម្ភសរុបចំនួន ១.២១២,៦៩ លានដុល្លារ ក្នុងកម្មវិធីជំនួយសាច់ប្រាក់សម្រាប់គ្រួសារមានប័ណ្ណសមធម៌ និងងាយរងគ្រោះកំឡុងពេលការរាតត្បាតជំងឺកូវីដ-១៩។

មូលនិធិសមធម៌សុខាភិបាល បានពង្រីកវិសាលភាពគ្របដណ្តប់ពលរដ្ឋចំនួន ៥ លាននាក់ ចាប់ពីថ្ងៃទី២៤ ខែតុលា ឆ្នាំ២០២៣ តទៅ។ ការពង្រីកវិសាលភាពនេះធ្វើឡើងដើម្បីធានាថា ពលរដ្ឋងាយរងគ្រោះ កម្មករនិយោជិតក្រៅប្រព័ន្ធ បុគ្គលស្វ័យនិយោជន៍ មន្ត្រីថ្នាក់ក្រោមជាតិ កីឡាករ-កីឡាការិនីជម្រើសជាតិ និងអ្នកផ្ទុកមេរោគអេសដ៍នឹងទទួលបានការត្រួតពិនិត្យសុខភាព និងព្យាបាល ដោយឥតគិតថ្លៃនៅតាមមូលដ្ឋានសុខាភិបាលសាធារណៈ។ រាល់ការចំណាយទាំងអស់ជាបន្ទុករបស់រដ្ឋាភិបាល (អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គមកម្ពុជា ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០២៣) ដោយប្រើទុនបម្រុងប្រមាណ ៨៦ លានដុល្លារ ក្នុងឆ្នាំ២០២៤។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រួមជាមួយក្រសួងកិច្ចការនារី និងក្រសួងអប់រំ យុវជន និងកីឡា កំពុងសិក្សាលទ្ធភាពក្នុងការបង្កើតទារកដ្ឋាន និងសាលាមត្តេយ្យសហគមន៍ នៅក្នុងបរិវេណរោងចក្រសហគ្រាស (ដកស្រង់ដោយកាសែតខ្មែរថាមស៍ ថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២៣)។

រាជរដ្ឋាភិបាលកម្ពុជា ត្រៀមថវិកាចំនួន ៣៦ លានដុល្លារ ដើម្បីផ្តល់ឱកាសបណ្តុះបណ្តាលដល់យុវជនក្រីក្រទូទាំងប្រទេស។ កម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈនេះ គ្រោងនឹងប្រកាសជាផ្លូវការក្នុងខែវិច្ឆិកា ឆ្នាំ២០២៣ ដែលនឹងផ្តល់អត្ថប្រយោជន៍ដល់យុវជនប្រមាណ ១,៥ លាននាក់ មកពីគ្រួសារក្រីក្រ និងងាយរងគ្រោះ (ដកស្រង់ដោយកាសែតខ្មែរថាមស៍ ថ្ងៃទី៣០ ខែតុលា ឆ្នាំ២០២៣)។

## គោលនយោបាយឆ្លើយតបផ្នែកសេដ្ឋកិច្ច

FAO សហការជាមួយក្រសួងនានា បើកដំណើរការគម្រោង PEARL ដែលជាគំនិតផ្តួចផ្តើម មានតម្លៃ ៤៣ លានដុល្លារ ដើម្បីលើកកម្ពស់និរន្តរភាពកសិកម្ម។ វានឹងជួយដល់កសិករខ្នាតតូចនៅតំបន់អាងទន្លេសាប ភាគខាងជើងរបស់កម្ពុជា តាមរយៈការដាំដុះដំណាំ ដែលមានតម្លៃខ្ពស់ផង បង្កើនឱកាសទីផ្សារផង និងចូលរួមកាត់បន្ថយភាពងាយរងគ្រោះនៃការប្រែប្រួលអាកាសធាតុផង (ដកស្រង់ដោយកាសែតភ្នំពេញប៉ុស្ដិ៍ ថ្ងៃទី៣០ ខែតុលា ឆ្នាំ២០២៣)។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (MAFF) បានចុះអនុស្សរណៈនៃការយោគយល់គ្នា (MoU) ជាមួយធនាគាររីងនៅថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២៣។ គោលបំណងនៃ MoU គឺពង្រឹងការអភិវឌ្ឍវិស័យកសិកម្ម តាមរយៈការផ្តល់កម្ចីដល់កសិករជាមួយនឹងប្រព័ន្ធ "Wingagri" (ដកស្រង់ដោយកាសែតខ្មែរថាមស៍ ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២៣)។




*ប្រភព៖ ទំព័រហ្វេសប៊ុកផ្លូវការរបស់អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម បិតផ្សាយនៅថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២៣*

**ចំនួនប្រជាជនបានចាក់វ៉ាក់សាំងកូវីដ-១៩**




*ប្រភព៖ ក្រសួងសុខាភិបាលកម្ពុជា ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២៣*

# វិធីសាស្ត្រ និងទីតាំងផ្សារ




WFP ចាប់ផ្តើមតាមដានតម្លៃស្បៀងអាហារ នៅតាមបណ្តាផ្សារមួយចំនួនតាមរយៈទូរស័ព្ទ តាំងពីខែវិច្ឆិកា ឆ្នាំ២០១៩ មកម្ល៉េះ។ អ្នកសម្ភាសន៍តាមទូរស័ព្ទ ដែលបានទទួលការបណ្តុះបណ្តាលច្បាស់លាស់បានទំនាក់ទំនងទៅកាន់អាជីវករនានា រៀងរាល់មួយខែម្តង ដើម្បីប្រមូលតម្លៃទំនិញចំនួន៣៦ប្រភេទ ក្នុងផ្សារចំនួន១៩ នៅទីប្រជុំជន និងជនបទនៃខេត្តបាត់ដំបង កំពង់ឆ្នាំង កំពង់ធំ ឧត្តរមានជ័យ សៀមរាប ព្រះវិហារ និងស្ទឹងត្រែង។

នៅក្រោមកិច្ចសហការជាមួយការិយាល័យទីផ្សារកសិកម្ម នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នៅខែមីនា ឆ្នាំ២០២០ WFP បានអង្កេតតម្លៃទីផ្សារនៅក្នុងផ្សារចំនួន៣១បន្ថែមទៀត ដើម្បីប្រមូលទិន្នន័យមូលដ្ឋាន និងដើម្បីពង្រីកចំនួនផ្សារគ្របដណ្តប់។ យើងបានប្រមូលតម្លៃស្បៀងចំនួន១៦ប្រភេទ និងព័ត៌មានពីដំណើរការរបស់ផ្សារទាំងនោះផងដែរ។

ចាប់ពីពាក់កណ្តាលខែមេសាឆ្នាំ២០២០មក WFP បានពង្រីកការតាមដានតម្លៃទីផ្សារតាមរយៈទូរស័ព្ទក្នុងផ្សារចំនួន៩៥ ហើយក៏បានបង្កើនចំនួនប្រមូលទិន្នន័យ ២ដងក្នុងមួយខែផងដែរ (ឧ. សប្តាហ៍ទី១ និងទី៣នៃខែនីមួយៗ)។

នៅពាក់កណ្តាលខែកញ្ញា ឆ្នាំ២០២២ WFP បន្ថែមទំនិញជាស្បៀងអាហារ និងមិនមែនស្បៀងអាហារចំនួន ១៥ (មើលឧបសម្ព័ន្ធ) និងពង្រីកផ្សារគ្របដណ្តប់ដល់ ៥៦ ផ្សារ។

# ឧបសម្ព័ន្ធទី១៖ បម្រែបម្រួលតម្លៃលក់រាយ

| ស្បៀងអាហារ | ខ្នាត | តម្លៃមធ្យមប្រចាំខែបច្ចុប្បន្ន | បម្រែបម្រួលតម្លៃធៀបនឹង១ខែមុន | បម្រែបម្រួលតម្លៃធៀបនឹង៣ខែមុន | បម្រែបម្រួលតម្លៃធៀបនឹង១ឆ្នាំមុន |
|---|---|---|---|---|---|
| ១.១ អង្ករចម្រុះ | Kg | 2,720 | → 0.7% | ↑ 23.9% | ↑ 28.8% |
| ២.១ ត្រីផ្ទក់(រស់) | Kg | 11,986 | → -0.2% | ↓ -6.1% | ↑ 15.4% |
| ២.២ ត្រីប្រា(រស់) | Kg | 7,459 | → 2.0% | → -0.8% | ↑ 5.9% |
| ២.៣ ត្រីអណ្តែង(រស់) | Kg | 8,163 | ↑ 5.7% | → 0.7% | → -2.1% |
| ២.៤ ត្រីងៀត(ផ្ទក់) | Kg | 27,395 | → 0.5% | → -2.2% | ↑ 6.5% |
| ២.៥ ប្រហុក | Kg | 8,962 | ↓ -6.3% | ↓ -10.4% | ↓ -15.0% |
| ៣.១ សាច់ជ្រូកពាជាន់ | Kg | 15,477 | → -0.2% | ↓ -5.4% | ↓ -14.0% |
| ៣.២ សាច់គោឃារ | Kg | 16,960 | → 0.4% | → 1.2% | ↓ -9.5% |
| ៣.៣ សាច់មាន់ (បីសាសន៍) | Kg | 14,571 | → -1.0% | ↑ 8.9% | ↑ 14.6% |
| ៤.១ ស៊ុតទា | 10 eggs | 5,778 | → 2.5% | ↓ -6.6% | ↓ -5.1% |
| ៤.២ ស៊ុតទាប្រៃ | 10 eggs | 7,244 | → 0.8% | → -4.8% | → -2.1% |
| ៥.១ ប្រេងឆា | 5 litres | 26,673 | → -0.6% | → -2.4% | ↓ -16.7% |
| ៦.១ អំបិលម៉ត់អ៊ីយូត | Kg | 1,267 | → 1.7% | ↑ 6.2% | → -3.2% |
| ៦.២ ទឹកត្រី (រូបបង្គងប៉ាក) | 730 ml | 3,432 | → 0.5% | → -0.6% | → 2.3% |
| ៧.១ សណ្តែកដី* | Kg | 9,928 | → -1.9% | → -0.2% | → 0.0% |
| ៧.២ សណ្តែកសៀង | Kg | 5,550 | → -3.6% | ↑ 5.7% | → 3.3% |
| ៧.៣ សណ្តែកខៀវ | Kg | 5,978 | → -1.4% | → -0.1% | → 0.9% |
| ៨.១ ត្រកួន | Kg | 3,263 | ↑ 11.1% | ↑ 11.5% | ↓ -29.7% |
| ៨.២ ការ៉ុត* | Kg | 3,157 | → -0.7% | → -5.0% | ↓ -12.0% |
| ៨.៣ ស្ពៃក្តោប ស្លឹកបាស* | Kg | 4,969 | ↑ 10.6% | ↑ 5.1% | → -3.6% |
| ៨.៤ ស្លឹកម្រុំ* | Kg | 5,205 | → 3.8% | → 2.4% | → -3.5% |
| ៨.៥ ស្ពៃក្រញាញ់* | Kg | 4,778 | ↑ 17.0% | ↑ 11.5% | ↓ -25.2% |
| ៨.៦ ស្ពៃតឿ* | Kg | 4,442 | ↑ 17.6% | ↑ 10.8% | ↓ -21.8% |
| ៨.៧ ស្ពៃចង្កឹះ | Kg | 4,156 | ↑ 24.1% | ↑ 10.6% | ↓ -17.4% |
| ៨.៨ ស្ពៃខៀវ* | Kg | 3,987 | ↑ 12.9% | ↑ 6.7% | ↓ -15.7% |
| ៨.៩ ផ្ទីដូង* | Kg | 4,205 | ↑ 17.6% | ↑ 9.6% | ↓ -25.4% |

| ស្បៀងអាហារ | ខ្នាត | តម្លៃមធ្យមប្រចាំខែបច្ចុប្បន្ន | បម្រែបម្រួលតម្លៃធៀបនឹង១ខែមុន | បម្រែបម្រួលតម្លៃធៀបនឹង៣ខែមុន | បម្រែបម្រួលតម្លៃធៀបនឹង១ឆ្នាំមុន |
|---|---|---|---|---|---|
| ៨.១០ ស្លឹកងប់* | Kg | 5,414 | → 0.2% | ↑ 7.5% | ↑ 30.4% |
| ៨.១១ ត្រយស្ពៅ* | Kg | 4,565 | ↓ -10.1% | ↓ -10.8% | ↑ 11.8% |
| ៨.១២ ផ្លែល្ពៅ* | Kg | 2,405 | → 2.4% | ↓ -5.4% | ↓ -18.8% |
| ៨.១៣ ឃ្លោក* | Kg | 2,614 | ↑ 14.9% | ● | ↓ -11.6% |
| ៨.១៤ ត្រឡាច | Kg | 2,500 | → 1.4% | → -4.1% | ↓ -27.4% |
| ៨.១៥ ត្រប់វែង | Kg | 2,991 | → 1.3% | → 3.8% | ↓ -21.3% |
| ៨.១៦ ត្រប់ស្រួយ* | Kg | 3,114 | ↑ 12.7% | ↑ 8.7% | ↓ -18.5% |
| ៨.១៧ ប៉េងប៉ោះ* | Kg | 4,067 | → -2.3% | ↑ 7.6% | ↓ -23.1% |
| ៨.១៨ ននោងមូល | Kg | 2,793 | → -5.0% | → -4.1% | ↓ -24.7% |
| ៨.១៩ ននោងជ្រុង* | Kg | 2,845 | ↓ -5.6% | ↓ -11.8% | ↓ -23.2% |
| ៨.២០ ល្ហុងខ្ចី* | Kg | 1,337 | → -3.1% | ↓ -23.9% | ↓ -5.7% |
| ៨.២១ សណ្តែកកួរ | Kg | 3,839 | ↑ 7.3% | → -0.2% | ↓ -9.4% |
| ៨.២២ ត្រយូងចេក* | Kg | 2,420 | → 4.5% | ↑ 12.7% | ↑ 8.9% |
| ៨.២៣ ផ្កាខាត់ណា* | Kg | 7,943 | → 3.4% | → -0.8% | ↓ -19.0% |
| ៨.២៤ ដើមខាត់ណា* | Kg | 6,056 | ↑ 34.4% | → -0.9% | ↓ -16.1% |
| ៨.២៥ ដំឡូងពណ៌លឿង* | Kg | 2,562 | ↓ -8.1% | ↓ -7.4% | → 1.1% |
| ៨.២៦ ខ្ទឹមសរ | Kg | 7,121 | → -2.8% | ↓ -6.5% | ↑ 33.9% |
| ៨.២៧ អំពិលទុំ (មានគ្រាប់) | Kg | 3,876 | ↓ -5.8% | → -4.0% | ↓ -13.0% |
| ៩.១ ចេកណាំវ៉ាទុំ | Kg | 2,265 | ↓ -5.4% | ↓ -8.9% | ↑ 8.4% |
| ៩.២ ស្វាយកែវរមៀតទុំ | Kg | 1,425 | ● | ↓ -55.0% | ↓ -71.5% |
| ១០.១ ទឹកដោះគោស្រស់ | 140 ml | 2,127 | ↑ 7.7% | → 4.7% | ↑ 27.1% |
| ១១.១ កូកាកូឡា | 330 ml | 2,000 | → 0.0% | → 0.6% | → 3.2% |
| ៧.១ សាំងធម្មតា | litre | 4,497 | → -1.9% | ↑ 8.2% | → 2.7% |
| ៧.២ ម៉ាស៊ូត | litre | 4,588 | → -0.2% | ↑ 17.5% | ↓ -6.5% |
| ៨.១ ជីអ៊ុយរ៉េ | Kg | 2,960 | → 0.7% | ↑ 6.6% | ↓ -23.2% |

*សម្គាល់៖ ទិន្នន័យនិងបម្រែបម្រួលតម្លៃ ដែលបានរាយការណ៍គឺជាតម្លៃជាក់ស្តែង ខ. តម្លៃរាយការណ៍ពីទីផ្សារផ្ទាល់។*

** តម្លៃនៃស្បៀងអាហារទាំងនេះ ត្រូវបានប្រមូលពីផ្សារក្នុងខេត្តដែលអនុវត្តកម្មវិធីផ្តល់អាហារលេតាមសាលារៀនដោយប្រើប្រាស់កសិផលពីសហគមន៍។*

ទិសដៅបម្រែបម្រួលធៀបជាមួយខែមុន និងឆ្នាំមុន៖

- ↑ កើនឡើង នៅពេលភាគរយបម្រែបម្រួលច្រើនជាង ៥%
- → ថេរ នៅពេលភាគរយបម្រែបម្រួលនៅចន្លោះពី ៥% និង -៥%
- ↓ ថយចុះ នៅពេលភាគរយបម្រែបម្រួលតិចជាង -៥%
- ● គ្មានតម្លៃកត់ត្រា

# ឧបសម្ព័ន្ធទី២៖ បម្រែបម្រួលតម្លៃលក់ដុំ

| ស្បៀងអាហារ | ខ្នាត | តម្លៃមធ្យមប្រចាំខែបច្ចុប្បន្ន | បម្រែបម្រួលតម្លៃធៀបនឹង ១ខែមុន | បម្រែបម្រួលតម្លៃធៀបនឹង ៣ខែមុន | បម្រែបម្រួលតម្លៃធៀបនឹង ១ឆ្នាំមុន |
|---|---|---|---|---|---|
| ១.១ អង្ករចម្រុះ | Kg | 2,569 | → 0.4% | ↑ 26.4% | ↑ 31.5% |
| ២.១ ត្រីផ្ទក់(រស់) | Kg | 10,779 | → -0.4% | ↓ -7.6% | ↑ 16.3% |
| ២.២ ត្រីប្រា(រស់) | Kg | 6,689 | → 2.7% | → -1.1% | ↑ 8.0% |
| ២.៣ ត្រីអណ្តែង(រស់) | Kg | 7,264 | ↑ 5.7% | → -0.7% | → -1.8% |
| ២.៤ ត្រីងៀត(ផ្ទក់) | Kg | 25,372 | → 1.0% | → -3.1% | ↑ 8.0% |
| ២.៥ ប្រហុក | Kg | 7,857 | ↓ -7.1% | ↓ -10.9% | ↓ -16.0% |
| ៣.១ សាច់ជ្រូកពាជាន់ | Kg | 14,220 | → 0.1% | ↓ -5.4% | ↓ -14.3% |
| ៣.២ សាច់គោឃារ | Kg | 15,260 | → 1.2% | → -1.0% | ↓ -10.9% |
| ៣.៣ សាច់មាន់ (បីសាសន៍) | Kg | 13,449 | → -1.3% | ↑ 11.5% | ↑ 18.4% |
| ៤.១ ស៊ុតទា | 10 eggs | 5,332 | → 2.4% | ↓ -8.4% | → -4.8% |
| ៤.២ ស៊ុតទាប្រៃ | 10 eggs | 6,647 | → 0.4% | ↓ -6.5% | → -3.1% |
| ៥.១ ប្រេងឆា | 5 litres | 25,428 | → -1.0% | → -3.2% | ↓ -17.7% |
| ៦.១ អំបិលម៉ត់អ៊ីយូត | Kg | 1,001 | → 1.5% | ↑ 5.6% | → -0.3% |
| ៦.២ ទឹកត្រី (ប្រូបង្គងប៉ាក) | 730 ml | 2,977 | → -1.3% | → 0.4% | → -0.3% |
| ៧.១ សណ្តែកដី* | Kg | 8,932 | → -3.2% | → -1.1% | → 0.3% |
| ៧.២ សណ្តែកសៀង | Kg | 4,909 | ↓ -8.0% | → 3.5% | → 0.3% |
| ៧.៣ សណ្តែកខៀវ | Kg | 5,498 | → -1.0% | → 0.0% | → 2.5% |
| ៨.១ ត្រកួន | Kg | 2,611 | ↑ 15.5% | ↑ 17.3% | ↓ -34.1% |
| ៨.២ ការ៉ុត* | Kg | 2,436 | → -3.6% | ↓ -9.7% | ↓ -18.4% |
| ៨.៣ ស្ពៃក្តោបបាស* | Kg | 3,717 | ↑ 8.3% | ↑ 11.8% | ↓ -8.2% |
| ៨.៤ ស្ពៃក្រម៉* | Kg | 3,808 | ↑ 8.2% | → 4.8% | ↓ -10.0% |
| ៨.៥ ម្ទេសក្រញាញ់* | Kg | 4,008 | ↑ 19.8% | ↑ 15.5% | ↓ -26.6% |
| ៨.៦ ម្ទេសតៀ* | Kg | 3,660 | ↑ 19.9% | ↑ 13.5% | ↓ -23.3% |
| ៨.៧ ម្ទេសចង្កឹះ | Kg | 3,469 | ↑ 30.9% | ↑ 13.4% | ↓ -17.7% |
| ៨.៨ ម្ទេសខៀវ* | Kg | 3,223 | ↑ 16.3% | ↑ 6.6% | ↓ -17.7% |
| ៨.៩ ផ្ទីដូង* | Kg | 3,162 | ↑ 13.3% | ↑ 6.9% | ↓ -29.5% |

| ស្បៀងអាហារ | ខ្នាត | តម្លៃមធ្យមប្រចាំខែបច្ចុប្បន្ន | បម្រែបម្រួលតម្លៃធៀបនឹង ១ខែមុន | បម្រែបម្រួលតម្លៃធៀបនឹង ៣ខែមុន | បម្រែបម្រួលតម្លៃធៀបនឹង ១ឆ្នាំមុន |
|---|---|---|---|---|---|
| ៨.១០ ស្ពៃកង់* | Kg | 3,993 | → 3.5% | → 2.6% | ↑ 15.4% |
| ៨.១១ ត្រយល្ពៅ* | Kg | 3,398 | ↓ -5.5% | ↓ -10.7% | → 0.9% |
| ៨.១២ ផ្លែល្ពៅ* | Kg | 1,864 | → 3.9% | → -2.5% | ↓ -21.4% |
| ៨.១៣ ឃ្លោក* | Kg | 2,127 | ↑ 33.4% | ● | ↓ -12.4% |
| ៨.១៤ ត្រឡាច | Kg | 1,926 | → 2.8% | → -0.6% | ↓ -31.8% |
| ៨.១៥ ត្រប់វែង | Kg | 2,420 | → 3.8% | ↑ 13.5% | ↓ -21.5% |
| ៨.១៦ ត្រប់ស្រួយ* | Kg | 2,379 | ↑ 13.1% | ↑ 14.2% | ↓ -23.5% |
| ៨.១៧ ប៉េងប៉ោះ* | Kg | 3,373 | → -2.9% | ↑ 14.5% | ↓ -24.8% |
| ៨.១៨ននោងមូល | Kg | 2,149 | → -3.9% | ↓ -7.1% | ↓ -26.4% |
| ៨.១៩ ននោងជ្រុង* | Kg | 2,135 | ↓ -10.7% | ↓ -16.9% | ↓ -27.9% |
| ៨.២០ ល្ហុងខ្ចី* | Kg | 907 | → -3.5% | ↓ -31.1% | ↓ -10.5% |
| ៨.២១ សណ្តែកកួរ | Kg | 3,134 | ↑ 8.5% | ↑ 5.2% | ↓ -8.7% |
| ៨.២២ ត្រយូងចេក* | Kg | 1,898 | ↑ 7.1% | ↑ 13.3% | ↑ 9.9% |
| ៨.២៣ ផ្កាខាត់ណា* | Kg | 7,013 | ↑ 8.6% | → -1.2% | ↓ -17.4% |
| ៨.២៤ ដើមខាត់ណា* | Kg | 5,235 | ↑ 43.7% | → 4.8% | ↓ -16.7% |
| ៨.២៥ ដំឡូងពណ៌លឿង* | Kg | 2,065 | ↓ -7.9% | → -4.8% | → 2.4% |
| ៨.២៦ ខ្ទឹមសរ | Kg | 6,532 | → -1.6% | ↓ -5.3% | ↑ 41.3% |
| ៨.២៧ អំពិលទុំ (មានគ្រាប់) | Kg | 3,317 | ↓ -5.5% | → -3.9% | ↓ -12.6% |
| ៩.១ ចេកណាំវ៉ាទុំ | Kg | 1,812 | ↓ -6.6% | ↓ -9.2% | ↑ 14.3% |
| ៩.២ ស្វាយកែវរមៀតទុំ | Kg | 1,025 | ● | ↓ -52.7% | ↓ -77.2% |
| ១០.១ ទឹកដោះគោស្រស់ | 140 ml | 1,909 | ↑ 10.0% | ↑ 14.3% | ↑ 31.1% |
| ១១.១ កូកាកូឡា | 330 ml | 1,570 | → 0.4% | → 2.3% | → -2.8% |
| ៧.១ សាំងធម្មតា | litre | 4,284 | → -1.8% | ↑ 13.6% | → 0.8% |
| ៧.២ ម៉ាស៊ូត | litre | 4,366 | → -1.4% | ↑ 17.1% | ↓ -9.6% |
| ៨.១ ជីអ៊ុយរ៉េ | Kg | 2,480 | → 0.9% | ↑ 9.6% | ↓ -27.4% |

*សម្គាល់៖ ទិន្នន័យនិងបម្រែបម្រួលតម្លៃ ដែលបានរាយការណ៍គឺជាតម្លៃជាក់ស្តែង ឧ. តម្លៃរាយការណ៍ពីទីផ្សារផ្ទាល់។*

** តម្លៃនៃស្បៀងអាហារទាំងនេះ ត្រូវបានប្រមូលពីផ្សារក្នុងខេត្តដែលអនុវត្តកម្មវិធីផ្តល់អាហារលេតាមសាលារៀនដោយប្រើប្រាស់កសិផលពីសហគមន៍។*

ទិសដៅបម្រែបម្រួលធៀបជាមួយខែមុន និងឆ្នាំមុន៖

- ↑ កើនឡើង នៅពេលភាគរយបម្រែបម្រួលច្រើនជាង ៥%
- → ថេរ នៅពេលភាគរយបម្រែបម្រួលនៅចន្លោះពី ៥% និង -៥%
- ↓ ថយចុះ នៅពេលភាគរយបម្រែបម្រួលតិចជាង -៥%
- ● គ្មានតម្លៃកត់ត្រា

# ឧបសម្ព័ន្ធទី៣៖ តម្លៃនៃកញ្ចប់ស្បៀងអាហារមូលដ្ឋាន

ការគណនាតម្លៃនៃកញ្ចប់ស្បៀងអាហារមូលដ្ឋាន ដែលបង្ហាញនៅក្នុងរបាយការណ៍នេះ ផ្អែកចម្បងលើការវិភាគកញ្ចប់ចំណាយអប្បបរមា (MEB) នៅប្រទេសកម្ពុជា។ ដើម្បីរៀបចំកញ្ចប់អាហារសម្រាប់ការវិភាគនេះ ក្រុមគ្រួសារគោលត្រូវបានវិភាគចេញពីទិន្នន័យអង្កេតសេដ្ឋកិច្ច សង្គមកិច្ច ឆ្នាំ២០១៩ ផ្អែកលើលក្ខខណ្ឌដូចខាងក្រោម៖

i. គ្រួសារដែលមានការចំណាយប្រចាំខែនៅចន្លោះបញ្ចភាគទី២ និងទី៤

ii. គ្រួសារមានសន្តិសុខស្បៀងគ្រប់គ្រាន់ (ពិន្ទុកម្រិតទទួលទានអាហារអាចទទួលយកបាន)

iii. គ្រួសារមិនបានប្រើប្រាស់យុទ្ធសាស្ត្រអវិជ្ជមានដើម្បីដោះស្រាយបញ្ហាខ្វះស្បៀង។

កញ្ចប់ស្បៀងអាហារសម្រាប់ក្រុមគ្រួសារគោលនេះ ត្រូវបានបង្កើតឡើងដើម្បីស្វែងយល់អំពីទម្រង់នៃការទទួលទានអាហារ ដែលសមស្របទៅនឹងអាហាររបស់គ្រួសារនីមួយៗគួរទទួលទាន ដើម្បីរស់នៅប្រកបដោយសុខភាពល្អ និងជីវិតសកម្ម។[1] ដូច្នេះ ស្បៀងអាហារជាក់លាក់ត្រូវបានកំណត់ ដើម្បីជាតំណាងឱ្យក្រុមអាហារនានាដែលមាននៅក្នុងផ្នែកការចំណាយលើស្បៀងអាហារ (សូមមើលតារាងទី២សម្រាប់បញ្ជីស្បៀងអាហារពេញ)។ ថាមពលគីឡូកាឡូរី និងបរិមាណស្បៀងត្រូវបានវិភាគចេញពីទិន្នន័យការចំណាយរបស់អង្កេតសេដ្ឋកិច្ច សង្គមកិច្ច ឆ្នាំ២០១៩ ដើម្បីកំណត់កម្រិតកាឡូរីមួយកញ្ចប់សម្រាប់មនុស្សម្នាក់ គួរទទួលទានដើម្បីរស់នៅប្រកបដោយសុខភាពល្អ និងជីវិតសកម្ម តាមទម្រង់សិទ្ធិទទួលបានជាមូលដ្ឋាន។

**តារាង២៖ សង្ខេបធាតុចូលសម្រាប់គណនាតម្លៃនៃកញ្ចប់ស្បៀងអាហារមូលដ្ឋាន**

| ក្រុមអាហារ[2] | ប្រភេទអាហារ[3] | ប្រភេទអាហារ[4] | គីឡូកាឡូរី/ម្នាក់/ថ្ងៃ[2] | ក្រាម/ម្នាក់/ថ្ងៃ[2] | រៀល/ក្រាម[4] | រៀល/ម្នាក់/ខែ[4] |
|---|---|---|---|---|---|---|
| Cereals | Rice | 1.1. អង្ករចម្រុះ/ Mixed Rice | 1,470.23 | 413.0 | 2.7 | 34,165 |
| Fish | Mud fish | 2.1. ត្រីផ្ទក់(រស់)/ Snakehead fish (Live) | 76.47 | 91.0 | 12.0 | 33,188 |
| Meat | Pork | 3.1. សាច់ជ្រូកពជាន់/ 3-layer pork/Pork with fat | 77.75 | 40.7 | 15.5 | 19,162 |
| Egg | Duck egg | 4.1. ស៊ុតទា/Duck egg | 21.92 | 11.8 | 9.2 | 3,331 |
| Diary | Milk | ---NA--- | 7 | 12.0 | --- | --- |
| Oil | Vegetable oil | 5.1. ប្រេងឆា/ Vegetable Oil: Saji ឬ Mongsay ឬ Cailan | 115.36 | 12.8 | 5.9 | 2,288 |
| Veg | Morning Glory | 8.1. ត្រកួន/ Morning glory | 34.76 | 231.7 | 3.3 | 23,001 |
| Tuber | Sweet Potato | 8.25. ដំឡូងផ្កាពណ៌លឿង/ Orange-flesh Sweet Potatoes | 19.21 | 19.6 | 2.6 | 1,528 |
| Pulses | Soybean/green bean | ---NA--- | 8 | 21.6 | --- | --- |
| Fruit | Banana | ---NA--- | 91 | 96.4 | --- | --- |
| | | **Total** | **1,937** | **950.6** | **---** | **116,663** |

ប្រភេទស្បៀងអាហារមួយចំនួនមិនត្រូវបានតាមដានដោយប្រព័ន្ធតាមដានទីផ្សាររបស់ WFP ដូច្នេះប្រភេទស្បៀងអាហារជាក់លាក់នោះមិនត្រូវបានរាប់បញ្ចូលនៅក្នុងកញ្ចប់ស្បៀងអាហារ ដែលបានតាមដាននៅក្នុងរបាយការណ៍នេះទេ។ ទោះជាយ៉ាងណា ទម្រង់នៃការបរិភោគស្បៀងអាហារនីមួយៗ (ទម្ងន់ គិតជា ក្រាម/ម្នាក់/ថ្ងៃ) អាចតំណាងឱ្យតម្លៃនៃម្ហូបអាហារប្រកបដោយអាហារូបត្ថម្ភ នៅក្នុងប្រទេសកម្ពុជា។

*[1] តម្លៃនៃកញ្ចប់ស្បៀងអាហារមូលដ្ឋាននៅក្នុងរបាយការណ៍បច្ចុប្បន្នភាពទីផ្សារនេះ មិនដូចគ្នា ជាមួយតម្លៃនៃកញ្ចប់ស្បៀងអាហាររបស់វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការប្រើសម្រាប់គណនាបន្ទាត់ភាពក្រីក្រថ្នាក់ជាតិឡើង។ កញ្ចប់ស្បៀងអាហារនៅក្នុងរបាយការណ៍នេះត្រូវបានគណនាដោយប្រើវិធីសាស្ត្រផ្សេង ហើយមានប្រយោជន៍ជាចម្បងសម្រាប់តម្លៃស្បៀងអាហារ។*

*[2] ការអង្កេតសេដ្ឋកិច្ច សង្គមកិច្ច ឆ្នាំ២០១៩ វិទ្យាស្ថានជាតិស្ថិតិ ប្រទេសកម្ពុជា។*

*[3] ការប៉ាន់ប្រមាណពីតម្លាតនៃការចំណាយ និងកញ្ចប់ចំណាយអប្បបរមានៅកម្ពុជា។ របាយការណ៍បច្ចេកទេស ខែមិថុនាឆ្នាំ២០២០ WFP ប្រចាំប្រទេសកម្ពុជា។*

*[4] បច្ចុប្បន្នភាពទីផ្សារ និងការតាមដានតាមរដូវកាល ខែតុលា ឆ្នាំ២០២៣ WFP ប្រចាំប្រទេសកម្ពុជា។*